# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល
# និង
# របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច

# អង្គការមូលនិធិអេស៊ីលីដា-ចារឌីនសម្រាប់ការអប់រំ

ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

**អង្គការមូលនិធិអេស៊ីលីដា-ចារឌីនសម្រាប់ការអប់រំ**

# មាតិកា


| | ទំព័រ |
|---|---|
| **របាយការណ៍របស់ក្រុមប្រឹក្សាភិបាល** | ១ - ៣ |
| **របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច** | |
| របាយការណ៍របស់សវនករឯករាជ្យ | ៤ - ៧ |
| របាយការណ៍ចំណូល និងចំណាយ | ៨ |
| កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ | ៩ - ១៤ |

## អង្គការមូលនិធិអេស៊ីលីដា-ចារឌីនសម្រាប់ការអប់រំ

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលអង្គការមូលនិធិអេស៊ីលីដា-ចារឌីនសម្រាប់ការអប់រំ (ហៅកាត់ថា "អេ ជេ អេហ្វ" ឬ "អង្គការ") សូមដាក់ជូននូវរបាយការណ៍របស់ខ្លួន ព្រមជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់អង្គការគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់។

### អំពីអង្គការ

អង្គការមូលនិធិអេស៊ីលីដា-ចារឌីនសម្រាប់ការអប់រំ ត្រូវបានបង្កើតឡើងក្នុងនាមជាអង្គការមិនមែនរដ្ឋាភិបាល អព្យាក្រឹត មិនរកប្រាក់ចំណេញ មិនរើសអើងក្នុងលក្ខណៈណាមួយ រួមទាំងសាសនា ពូជសាសន៍ និងបុគ្គលពាក់ព័ន្ធនយោបាយ បុគ្គលមិនពាក់ព័ន្ធនយោបាយ រួមទាំងការមិនធ្វើជាឧបករណ៍នយោបាយ ដោយផ្គត់ផ្គង់សម្ភារ ហិរញ្ញវត្ថុ ធនធានមនុស្សក្នុងការចូលរួមក្នុងសកម្មភាពណាមួយដែលគាំទ្រគណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រណាមួយឡើយ។

អនុស្សរណៈយោគយល់គ្នារវាងធនាគារអេស៊ីលីដា ភីអិលស៊ី និង JSH Asian Holding Limited ("Jardines") ត្រូវបានចុះហត្ថលេខានៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦។ លក្ខន្តិកៈរបស់ អេ ជេ អេហ្វ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ និងក្រសួងមហាផ្ទៃ ("MOI") នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨។

នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២ អង្គការបានធ្វើវិសោធនកម្មលើអនុស្សរណៈរបស់ខ្លួនដើម្បីដាក់បញ្ចូលក្រុមហ៊ុនហ្សតតេ អ៊ិនស្វឺរ៉ិនស៍ (ខេមបូឌា) ភីអិលស៊ី ក្នុងនាមជាស្ថាបនិកថ្មី។ វិសោធនកម្មនេះត្រូវបានអនុម័តដោយក្រសួងមហាផ្ទៃនៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៣។

នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០២៣ និយ័តករបរធនបាលកិច្ចបានផ្តល់ការចុះបញ្ជីបរធនបាលកិច្ចសង្គមរបស់អង្គការក្រោមវិញ្ញាបនបត្រលេខ ០០១ ន.ប.ធ/វ.ច./ប.ស.។ អនុលោមតាមច្បាប់ស្តីពីបរធនបាលកិច្ចកម្ពុជា អង្គការក្នុងនាមជាបរធនបាលកិច្ចសង្គមត្រូវបានការពារដោយស្របច្បាប់ និងត្រូវបានត្រួតពិនិត្យសម្រាប់មូលនិធិទាំងអស់ដែលអង្គការទទួលបានពីសប្បុរសជននានា សម្រាប់បម្រើដល់សកម្មភាពសង្គម និងមនុស្សធម៌របស់ខ្លួន។

គោលបំណងរបស់អង្គការ គឺដើម្បីជួយដល់សិស្សដែលមានសិទ្ធិអាចទទួលបាននៅតាមតំបន់ជនបទ និងតំបន់ដែលមានភាពខ្សត់ខ្សោយនៃប្រទេសកម្ពុជា ដែលពុំមានមធ្យោបាយក្នុងការទទួលបានការសិក្សាថ្នាក់បឋម និងមធ្យម ដើម្បីជំរុញ និងបន្តការអប់រំរបស់ពួកគេ និងដើម្បីកែលម្អមូលដ្ឋានគ្រឹះនៃការអប់រំនៅតំបន់ជនបទ និងតំបន់ដែលមានភាពខ្សត់ខ្សោយនៃប្រទេសកម្ពុជា ដោយកំណត់គោលដៅអភិវឌ្ឍន៍សាលារៀន ការបញ្ជូនគ្រូបង្រៀនតាមការសមស្រប បរិក្ខារ អគារ និងហេដ្ឋារចនាសម្ព័ន្ធអប់រំទាំងមូល។

អង្គការមានទីតាំងស្ថិតនៅអគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

## ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលរបស់អង្គការក្នុងអំឡុងការិយបរិច្ឆេទ និងរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះមានដូចខាងក្រោម៖

| **ឈ្មោះ** | **មុខតំណែង** | **កាលបរិច្ឆេទនៃការតែងតាំង / (លាលែងពីតំណែង)** |
|---|---|---|
| បណ្ឌិត ព្រំ វិសុទ្ធ | ប្រធានក្រុមប្រឹក្សាភិបាល | ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ |
| លោក Peter Beynon | អនុប្រធាន | ថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៧ |
| លោក ហួរ រតនៈ | សមាជិក | ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២ |
| លោក យក់ ចំរើនឫទ្ធិ | សមាជិក | ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ |
| អ្នកស្រី ហេង ភួងអ៊ាង | សមាជិក | ថ្ងៃទី២ ខែសីហា ឆ្នាំ២០២៣ |
| លោក Alan Xavier Cany | សមាជិក | ថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៧ / (ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣) |
| បណ្ឌិត សូ ផនណារី | សមាជិក | ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ / (ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣) |

## ប្រភពសំខាន់ៗនៃសាច់ប្រាក់ និងធនធានរបស់អង្គការ និងវិធីសាស្រ្តសំខាន់ៗដែលអង្គការប្រើប្រាស់ដើម្បីរៃអង្គាសមូលនិធិ

អង្គការរៃអង្គាសប្រាក់ពីស្ថាបនិក និងក្រុមហ៊ុនដែលពាក់ព័ន្ធ និងអ្នកធ្វើអំណោយឯកត្តជន និងរួមគ្នា។ រាល់ប្រាក់ដែលបានរៃអង្គាសត្រូវបានគ្រប់គ្រង និងចាត់ចែងដោយបុគ្គលិកមានជំនាញវិជ្ជាជីវៈ ដើម្បីធានាថារាល់ប្រាក់មួយដុល្លារៗដែលបានចំណាយ គឺសម្រេចបាននូវចក្ខុវិស័យរបស់ អេ ជេ អេហ្វ ដើម្បីផ្ដល់ឱកាសឱ្យស្មើគ្នាសម្រាប់ការអប់រំដល់កុមារកម្ពុជាទាំងអស់។

## សវនករ

របាយការណ៍ហិរញ្ញវត្ថុរបស់អង្គការគិតត្រឹមទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃ ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុនសួងការគណនេយ្យ ប្រេគ្គន សនថុន (ខេមបូឌា) លីមីធីត។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវចំពោះរបាយការណ៍ហិរញ្ញវត្ថុដែលបង្ហាញពីរបាយការណ៍ចំណូល និងចំណាយរបស់អង្គការគិតត្រឹមទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ត្រូវបានរៀបចំឡើងដោយផ្ដល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវជាសារវន្តតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជា សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ ("CFRS for NFPEs")។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលតម្រូវឱ្យ៖

១. ជ្រើសរើសគោលនយោបាយគណនេយ្យដែលសមស្រប និងត្រូវយកមកអនុវត្តប្រកបដោយសង្គតិភាព

២. ធានាថាកំណត់ត្រាគណនេយ្យត្រូវបានរក្សាទុក និងរៀបចំយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុអង្គការដោយអនុលោមតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជា សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ

៣. ធានានូវភាពពេញលេញនៃព័ត៌មានទាក់ទងនឹងទ្រព្យសម្បត្តិ និងបរិក្ខារ ដែលជាកម្មសិទ្ធិរបស់អង្គការ និង

៤. រក្សាទុកកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់  និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព។

ក្រុមប្រឹក្សាភិបាល ក៏ជាអ្នកទទួលខុសត្រូវក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់អង្គការ ហើយក៏ត្រូវចាត់វិធានការឱ្យសមស្របដើម្បីទប់ស្កាត់ និងរកឱ្យឃើញនៅការក្លែងបន្លំ និងភាពមិនប្រក្រតីផ្សេងៗ។

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការផ្តល់ និងបានផ្តល់ជូនសវនករនូវរាល់កំណត់ត្រាគណនេយ្យ ឯកសារយោង និងឯកសារផ្សេងៗ កំណត់ហេតុ និងរាល់ព័ត៌មាន និងការបកស្រាយដែលពាក់ព័ន្ធណាមួយ ដែលបញ្ជាក់ដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរដែលចាំបាច់សម្រាប់ការធ្វើសវនកម្ម។

**សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល**

របាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយបង្ហាញនូវទិដ្ឋភាពពិតនិងត្រឹមត្រូវជាសារវន្ត ដែលរួមមានចំណូល និងចំណាយរបស់អង្គការ សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ដោយអនុលោមតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជា សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ ។

ជំនួសឱ្យក្រុមប្រឹក្សាភិបាលរបស់អង្គការ៖

---------------------------

**បណ្ឌិត ព្រំ វិសុទ្ធ**

ប្រធានក្រុមប្រឹក្សាភិបាល

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤

Grant Thornton

**ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត**
ជាន់ទី២០ អគារកាណាឌីយ៉ា
៣១៥ ផ្លូវព្រះអង្គឌួង
(កែងមហាវិថីព្រះមុនីវង្ស)
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
លេខទូរស័ព្ទ +៨៥៥ ២៣ ៩៦៦ ៥២០

# របាយការណ៍របស់សវនករឯករាជ្យ

## ជូនចំពោះក្រុមប្រឹក្សាភិបាលរបស់ អង្គការមូលនិធិអេស៊ីលីដា-ចារឌីនសម្រាប់ការអប់រំ

### មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គការមូលនិធិអេស៊ីលីដា-ចារឌីនសម្រាប់ការអប់រំ (ហៅកាត់ថា "អង្គការ") ដែលរួមមានរបាយការណ៍ចំណូល និងចំណាយ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងសេចក្ដីសង្ខេបគោលនយោបាយគណនេយ្យសំខាន់ៗ និងសេចក្ដីពន្យល់ព័ត៌មានផ្សេងៗ។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវជាសារវន្តពីសមតុល្យមូលនិធិរបស់អង្គការ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងរបាយការណ៍ចំណូល និងចំណាយសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជា សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ ("CFRS for NFPEs")។

### មូលដ្ឋាននៃការបញ្ចេញមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា ("CISAs")។ ការទទួលខុសត្រូវរបស់យើងខ្ញុំស្ថិតក្រោមស្តង់ដាទាំងនោះ គឺត្រូវបានរៀបរាប់បន្ថែមនៅក្នុងផ្នែកការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុនៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំមានឯករាជ្យភាពពីអង្គការ ដោយអនុលោមតាមក្រុមប្រឹក្សាស្តង់ដាវិជ្ជាជីវៈគណនេយ្យអន្តរជាតិ ក្រមសីលធម៌របស់គណនេយ្យករជំនាញ (រួមទាំងស្តង់ដាឯករាជ្យអន្តរជាតិ) ("IESBA Code") រួមជាមួយនឹងតម្រូវការក្រមសីលធម៌ ដែលពាក់ព័ន្ធទៅនឹងការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញនូវការទទួលខុសត្រូវទៅតាមតម្រូវការក្រមសីលធម៌ទាំងនោះ និងIESBA Code។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្ម ដែលយើងខ្ញុំទទួលបាន គឺគ្រប់គ្រាន់ និងសមស្របដើម្បីផ្តល់មូលដ្ឋានសម្រាប់មតិយោបល់របស់យើងខ្ញុំ។



**គណនេយ្យករជំនាញ និងសវនករប្រតិស្រុត**
ក្រុមហ៊ុន ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត គឺជាសមាជិករបស់ក្រុមហ៊ុនហ្គ្រេន សនថុន អន្តរជាតិ (ហ្គ្រេន សនថុន អន្តរជាតិ)។ ហ្គ្រេន សនថុន គឺសំដៅដល់ឈ្មោះដែលសមាជិករបស់ក្រុមហ៊ុនហ្គ្រេន សនថុនធ្វើប្រតិបត្តិការ និងសំដៅដល់ក្រុមហ៊ុនមួយ ឬក្រុមហ៊ុនជាសមាជិកច្រើន តាមបរិបទតម្រូវ។ ហ្គ្រេន សនថុន អន្តរជាតិ និងសមាជិកមិនមែនជាដៃគូពាណិជ្ជកម្មទូទាំងសកលលោកទេ។ រាល់សេវាកម្មនានាត្រូវបានផ្តល់យ៉ាងឯករាជ្យដោយសមាជិកនីមួយៗ ហើយសេវាកម្ម ឬសកម្មភាពនៃសមាជិកនីមួយៗមិនមែនជាការទទួលខុសត្រូវរបស់ក្រុមហ៊ុនហ្គ្រេន សនថុនផ្សេងទៀតទេ។

grantthornton.com.kh

## ព័ត៌មានផ្សេងៗ

ក្រុមប្រឹក្សាភិបាល មានទំនួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗទាំងនោះ រួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ប៉ុន្តែមិនរួមបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គការ និងរបាយការណ៍សវនកម្មរបស់យើងខ្ញុំឡើយ។

មតិយោបល់របស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗទេ ហើយយើងខ្ញុំមិនផ្តល់នូវសេចក្តីសន្និដ្ឋានក្នុងទម្រង់នៃការធានាបែបណាមួយឡើយ។

ភ្ជាប់ជាមួយការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គការ យើងខ្ញុំមានទំនួលខុសត្រូវក្នុងការអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានវិសមភាពជាសារវន្តជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុឬទេ ឬចំណេះដឹងរបស់យើងខ្ញុំដែលទទួលបានពីការធ្វើសវនកម្មថាតើព័ត៌មានទាំងនោះអាចមានកំហុសឆ្គងជាសារវន្តឬទេ។

ប្រសិនបើផ្អែកតាមការងារដែលយើងខ្ញុំបានអនុវត្ត យើងខ្ញុំសន្មតថាមានកំហុសជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗទាំងនេះ យើងខ្ញុំតម្រូវឱ្យធ្វើការរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំមិនមានអ្វីត្រូវរាយការណ៍នៅក្នុងករណីនេះឡើយ។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងរបស់អង្គការមានទំនួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជា សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុងដែលគណៈគ្រប់គ្រងកំណត់ថាវាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុពុំឱ្យមានការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងមានទំនួលខុសត្រូវចំពោះការវាយតម្លៃសមត្ថភាពរបស់អង្គការក្នុងការបន្តប្រតិបត្តិការដោយផ្អែកលើមូលដ្ឋាននិរន្តរភាព ការលាតត្រដាង ប្រសិនបើមានបញ្ហាទាក់ទងនឹងនិរន្តរភាព និងការប្រើប្រាស់មូលដ្ឋាននិរន្តរភាពជាមូលដ្ឋានគណនេយ្យ លុះត្រាតែគណៈគ្រប់គ្រងមានគោលបំណងរំសាយអង្គការ ឬបញ្ឈប់ប្រតិបត្តិការ ឬក៏គ្មានជម្រើសផ្សេង ប៉ុន្តែចាំបាច់ត្រូវធ្វើ។

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គការ។

## ការទទួលខុសត្រូវរបស់សវនករទៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដ៏សមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុទាំងមូលពុំមានលក្ខណៈខុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង ហើយក្នុងការបញ្ចេញមតិយោបល់លើរបាយការណ៍របស់សវនករ ដែលរួមមានមតិយោបល់របស់យើងខ្ញុំ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាអះអាងកម្រិតខ្ពស់ ប៉ុន្តែវាមិនបានធានាថាការធ្វើសវនកម្មដោយអនុលោមតាមស្តង់ដាសវនកម្មអន្តរជាតិរបស់កម្ពុជានឹងតែងតែរកឃើញកំហុសខុសឆ្គងជាសារវន្តនៅពេលវាកើតឡើងនោះទេ។ ការរាយការណ៍ខុសអាចកើតមានឡើងពីការក្លែងបន្លំ ឬកំហុសឆ្គងដែលអាចចាត់ទុកថាជាសារវន្ត នៅពេលដែលកំហុសមួយ ឬកំហុសរួមគ្នាបានធ្វើឱ្យប៉ះពាល់ដល់សេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនេះ។



**គណនេយ្យករជំនាញ និងសវនករប្រតិស្រុត**
ក្រុមហ៊ុន ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត គឺជាសមាជិករបស់ក្រុមហ៊ុនហ្គ្រេន សនថុន អន្តរជាតិ (ហ្គ្រេន សនថុន អន្តរជាតិ)។ ហ្គ្រេន សនថុន គឺសំដៅដល់ឈ្មោះដែលសមាជិករបស់ក្រុមហ៊ុនហ្គ្រេន សនថុនធ្វើប្រតិបត្តិការ និងសំដៅដល់ក្រុមហ៊ុនមួយ ឬក្រុមហ៊ុនជាសមាជិកច្រើន តាមបរិបទតម្រូវ។ ហ្គ្រេន សនថុន អន្តរជាតិ និងសមាជិកមិនមែនជាដៃគូពាណិជ្ជកម្មទូទាំងសកលលោកទេ។ រាល់សេវាកម្មនានាត្រូវបានផ្តល់យ៉ាងឯករាជ្យដោយសមាជិកនីមួយៗ ហើយសេវាកម្ម ឬសកម្មភាពនៃសមាជិកនីមួយៗមិនមែនជាការទទួលខុសត្រូវរបស់ក្រុមហ៊ុនហ្គ្រេន សនថុនផ្សេងទៀតទេ។

Grant Thornton

ជាផ្នែកមួយនៃការធ្វើសវនកម្មដោយយោងទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវវិជ្ជាជីវៈវិនិច្ឆ័យ និងរក្សាមជ្ឈធាតុនិយមប្រកបដោយវិជ្ជាជីវៈទៅលើការធ្វើសវនកម្ម។ យើងខ្ញុំក៏៖

- កំណត់អត្តសញ្ញាណ និងវាយតម្លៃនូវហានិភ័យនៃការរាយការណ៍ខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ថាតើវាកើតឡើងដោយការក្លែងបន្លំ ឬកំហុសឆ្គងដោយអចេតនា ការរៀបចំ និងអនុវត្តនីតិវិធីសវនកម្ម ដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ រួមទាំងការប្រមូលយកភស្តុតាងសវនកម្មឱ្យបានគ្រប់គ្រាន់ និងសមស្រប ដើម្បីជាមូលដ្ឋានសម្រាប់បញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញដោយការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ គឺធំជាងកំហុសឆ្គងដោយអចេតនាដោយសារតែការក្លែងបន្លំរួមបញ្ចូលទាំងការរួមគំនិត ការក្លែងបន្លំដោយចេតនា ការលុបចោលដោយចេតនា ការបង្ហាញខុស ឬការល្មើសទៅលើការត្រួតពិនិត្យផ្ទៃក្នុង។

- ធ្វើការស្វែងយល់អំពីការគ្រប់គ្រងផ្ទៃក្នុងដែលទាក់ទងទៅនឹងការធ្វើសវនកម្ម ដើម្បីបង្កើតនូវនីតិវិធីសវនកម្មដែលសមស្របទៅនឹងកាលៈទេសៈ ប៉ុន្តែមិនមែនជាគោលបំណងក្នុងការបង្ហាញនូវមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់អង្គការនោះទេ។

- ធ្វើការវាយតម្លៃភាពសមស្របលើគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មាន ក៏ដូចជាការបង្ហាញនានាដែលធ្វើឡើងដោយគណៈគ្រប់គ្រង។

- ធ្វើការសន្និដ្ឋានដ៏សមស្របលើការប្រើប្រាស់របស់គណៈគ្រប់គ្រងលើមូលដ្ឋាននិរន្តរភាពគណនេយ្យ ផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបានថាតើភាពមិនប្រាកដប្រជាជាសារវន្តបានកើតឡើងទាក់ទិននឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលធ្វើឱ្យមានមន្ទិលសង្ស័យខ្លាំងទៅលើលទ្ធភាពការបន្តនិរន្តរភាពរបស់អង្គការ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា ភាពមិនប្រាកដប្រជាជាសារវន្តនឹងកើតមានឡើង យើងខ្ញុំតម្រូវឱ្យធ្វើការលាតត្រដាងព័ត៌មានចាំបាច់ដើម្បីទាញការយកចិត្តទុកដាក់នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំទៅនឹងការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬក៏ប្រសិនបើការលាតត្រដាងនោះមិនគ្រប់គ្រាន់ នោះមតិយោបល់មិនត្រឹមត្រូវនឹងត្រូវបានផ្តល់។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបានគិតត្រឹមថ្ងៃនៃការចេញរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ទោះបីយ៉ាងណាក៏ដោយស្ថានភាព ឬក៏ព្រឹត្តិការណ៍នាពេលអនាគតអាចបណ្តាលឱ្យអង្គការមិនអាចបន្តប្រតិបត្តិការជានិរន្តរភាពបាន។

- វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងមាតិកានៃរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គការ រួមបញ្ចូលទាំងការលាតត្រដាងក្នុងកំណត់សម្គាល់ថាតើរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គការបង្ហាញនូវប្រតិបត្តិការ និងព្រឹត្តិការណ៍នានាដោយអនុលោមតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជា សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញដែរឬទេ។



**គណនេយ្យករជំនាញ និងសវនករប្រតិស្រុត**
ក្រុមហ៊ុន ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត គឺជាសមាជិករបស់ក្រុមហ៊ុនហ្គ្រេន សនថុន អន្តរជាតិ (ហ្គ្រេន សនថុន អន្តរជាតិ)។ ហ្គ្រេន សនថុន គឺសំដៅដល់ឈ្មោះដែលសមាជិករបស់ក្រុមហ៊ុនហ្គ្រេន សនថុនធ្វើប្រតិបត្តិការ និងសំដៅដល់ក្រុមហ៊ុនមួយ ឬក្រុមហ៊ុនជាសមាជិកច្រើន តាមបរិបទតម្រូវ។ ហ្គ្រេន សនថុន អន្តរជាតិ និងសមាជិកមិនមែនជាដៃគូពាណិជ្ជកម្មទូទាំងសកលលោកទេ។ រាល់សេវាកម្មនានាត្រូវបានផ្តល់យ៉ាងឯករាជ្យដោយសមាជិកនីមួយៗ ហើយសេវាកម្ម ឬសកម្មភាពនៃសមាជិកនីមួយៗមិនមែនជាការទទួលខុសត្រូវរបស់ក្រុមហ៊ុនហ្គ្រេន សនថុនផ្សេងទៀតទេ។

grantthornton.com.kh

យើងខ្ញុំប្រាស្រ័យទាក់ទងជាមួយនឹងក្រុមប្រឹក្សាភិបាលទៅលើបញ្ហាផ្សេងៗ កំណត់វិសាលភាព និងពេលវេលាក្នុងការធ្វើសវនកម្ម និងរបកគំហើញសវនកម្មសំខាន់ៗ រួមបញ្ចូលទាំងកង្វះខាតសំខាន់ៗមួយចំនួនទៅលើការគ្រប់គ្រងផ្ទៃក្នុងដែលយើងខ្ញុំបានរកឃើញអំឡុងពេលធ្វើសវនកម្ម។

Grant Thornton

**ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត**
គណនេយ្យករជំនាញ
សវនករប្រតិស្រុតចុះបញ្ជី

**Ronald C. Almera**
នាយកសវនករជំនាញ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤



គណនេយ្យករជំនាញ និងសវនករប្រតិស្រុត
ក្រុមហ៊ុន ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត គឺជាសមាជិករបស់ក្រុមហ៊ុនហ្គ្រេន សនថុន អន្តរជាតិ (ហ្គ្រេន សនថុន អន្តរជាតិ)។ ហ្គ្រេន សនថុន គឺសំដៅដល់ឈ្មោះដែលសមាជិករបស់ក្រុមហ៊ុនហ្គ្រេន សនថុនធ្វើប្រតិបត្តិការ និងសំដៅដល់ក្រុមហ៊ុនមួយ ឬក្រុមហ៊ុនជាសមាជិកច្រើន តាមបរិបទតម្រូវ។ ហ្គ្រេន សនថុន អន្តរជាតិ និងសមាជិកមិនមែនជាដៃគូពាណិជ្ជកម្មទូទាំងសកលលោកទេ។ រាល់សេវាកម្មនានាត្រូវបានផ្តល់យ៉ាងឯករាជ្យដោយសមាជិកនីមួយៗ ហើយសេវាកម្ម ឬសកម្មភាពនៃសមាជិកនីមួយៗមិនមែនជាការទទួលខុសត្រូវរបស់ក្រុមហ៊ុនហ្គ្រេន សនថុនផ្សេងទៀតទេ។

**អង្គការមូលនិធិអេស៊ីលីដា-ចារឌីនសម្រាប់ការអប់រំ**
**របាយការណ៍ចំណូល និងចំណាយ**
**គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់**

| | កំណត់សម្គាល់ | **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** ដុល្លារអាមេរិក | **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** ពាន់រៀល (កំណត់សម្គាល់ ២.២) | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដុល្លារអាមេរិក | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ពាន់រៀល (កំណត់សម្គាល់ ២.២) |
|---|---|---|---|---|---|
| **ចំណូលពីប្រតិបត្តិការ** | | | | | |
| ចំណូលបានពីការបរិច្ចាគ | | **៧៤.៥១៤** | **៣០៦.២៥៣** | ១៦៩.៩៦២ | ៦៩៤.៦៣៥ |
| ចំណូលការប្រាក់ និងចំណូលផ្សេងៗ | ៣ | **៣៧.០៤៦** | **១៥២.២៥៩** | ៣០.៩១០ | ១២៦.៣២៩ |
| **ចំណូលពីប្រតិបត្តិការសរុប** | | **១១១.៥៦០** | **៤៥៨.៥១២** | ២០០.៨៧២ | ៨២០.៩៦៤ |
| **ចំណាយប្រតិបត្តិការ** | | | | | |
| ការបរិច្ចាគ - អគារ និងបរិក្ខារសិក្សា | | **២១៣.៨៥៦** | **៨៧៨.៩៤៨** | ១៤៩.១៥៣ | ៦០៩.៥៨៨ |
| ការទូទាត់កម្រៃសេវារដ្ឋបាល | ៤ | **១២.៤២៩** | **៥១.០៨៣** | ៤.៦៣១ | ១៨.៩២៧ |
| ចំណាយទាក់ទងនឹងអ្នកស្ម័គ្រចិត្ត និងនិយោជិត | ៥ | **-** | **-** | ១.៥០១ | ៦.១៣៥ |
| **ចំណាយប្រតិបត្តិការសរុប** | | **២២៦.២៨៥** | **៩៣០.០៣១** | ១៥៥.២៨៥ | ៦៣៤.៦៥០ |
| **ប្រតិបត្តិការ (ឱនភាព)/អតិរេក** | | **(១១៤.៧២៥)** | **(៤៧១.៥២០)** | ៤៥.៥៨៧ | ១៨៦.៣១៤ |
| **(ថយចុះ)/កើនឡើងនូវសមតុល្យមូលនិធិ សុទ្ធ** | | **(១១៤.៧២៥)** | **(៤៧១.៥២០)** | ៤៥.៥៨៧ | ១៨៦.៣១៤ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | **-** | **(២៨.០១៨)** | - | ៤០.៩១២ |
| សាច់ប្រាក់ក្នុងធនាគារ ដើមការិយបរិច្ឆេទ | | **៩៦៥.២១១** | **៣.៩៧៣.៧៧៤** | ៩១៩.៦២៤ | ៣.៧៤៦.៥៤៨ |
| សមតុល្យមូលនិធិ ចុងការិយបរិច្ឆេទ | | **៨៥០.៤៨៦** | **៣.៤៧៤.២៣៦** | ៩៦៥.២១១ | ៣.៩៧៣.៧៧៤ |
| **តំណាងដោយ៖** | | | | | |
| សាច់ប្រាក់ក្នុងធនាគារ | ៦ | **៨៣១.១៦២** | **៣.៣៩៥.២៩៧** | ៩៤៥.៨៨៧ | ៣.៨៩៤.២១៧ |
| ប្រាក់តម្កល់តាមបទប្បញ្ញត្តិ | ៧ | **១៩.៣២៤** | **៧៨.៩៣៩** | ១៩.៣២៤ | ៧៩.៥៥៧ |
| **សមតុល្យមូលនិធិសរុប** | | **៨៥០.៤៨៦** | **៣.៤៧៤.២៣៦** | ៩៦៥.២១១ | ៣.៩៧៣.៧៧៤ |

**អង្គការមូលនិធិអេស៊ីលីដា-ចារឌីនសម្រាប់ការអប់រំ**
**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ**
**គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់**

## ១ អំពីអង្គការ

អង្គការមូលនិធិអេស៊ីលីដា-ចារឌីនសម្រាប់ការអប់រំ (ហៅកាត់ថា "អេ ជេ អេហ្វ" ឬ "អង្គការ") ត្រូវបានបង្កើតឡើងក្នុងនាមជាអង្គការមិនមែនរដ្ឋាភិបាល អព្យាក្រឹត មិនរកប្រាក់ចំណេញ មិនរើសអើងក្នុងលក្ខណៈណាមួយ រួមទាំងសាសនា ពូជសាសន៍ និងបុគ្គលពាក់ព័ន្ធនយោបាយ បុគ្គលមិនពាក់ព័ន្ធនយោបាយ រួមទាំងការមិនធ្វើជាឧបករណ៍នយោបាយ ដោយផ្គត់ផ្គង់សម្ភារ ហិរញ្ញវត្ថុ ធនធានមនុស្សក្នុងការចូលរួមក្នុងសកម្មភាពណាមួយដែលគាំទ្រគណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រណាមួយឡើយ។

អនុស្សរណៈយោគយល់គ្នារវាងធនាគារអេស៊ីលីដា ភីអិលស៊ី និង JSH Asian Holding Limited ("Jardines") ត្រូវបានចុះហត្ថលេខានៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦។ លក្ខន្តិកៈរបស់ អេ ជេ អេហ្វ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ និងក្រសួងមហាផ្ទៃនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨។

នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២ អង្គការបានធ្វើវិសោធនកម្មលើអនុស្សរណៈរបស់ខ្លួនដើម្បីដាក់បញ្ចូលក្រុមហ៊ុនហ្ស៊តេ អ៊ិនស្វឺរីនស៍ (ខេមបូឌា) ភីអិលស៊ី ក្នុងនាមជាស្ថាបនិកថ្មី។ វិសោធនកម្មនេះត្រូវបានអនុម័តដោយក្រសួងមហាផ្ទៃនៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៣។

នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០២៣ និយ័តករបរធនបាលកិច្ចបានផ្តល់ការចុះបញ្ជីបរធនបាលកិច្ចសង្គមរបស់អង្គការក្រោមវិញ្ញាបនបត្រលេខ ០០១ ន.ប.ធ/វ.ច./ប.ស.។ អនុលោមតាមច្បាប់ស្តីពីបរធនបាលកិច្ចកម្ពុជា អង្គការក្នុងនាមជាបរធនបាលកិច្ចសង្គមត្រូវបានការពារដោយស្របច្បាប់ និងត្រូវបានត្រួតពិនិត្យសម្រាប់មូលនិធិទាំងអស់ដែលអង្គការទទួលបានពីសប្បុរសជននានា សម្រាប់បម្រើដល់សកម្មភាពសង្គម និងមនុស្សធម៌របស់ខ្លួន។

គោលបំណងរបស់អង្គការ គឺដើម្បីជួយដល់សិស្សដែលមានសិទ្ធិអាចទទួលបាននៅតាមតំបន់ជនបទ និងតំបន់ដែលមានភាពខ្វះខាតខ្សោយនៃប្រទេសកម្ពុជា ដែលពុំមានមធ្យោបាយក្នុងការទទួលបានការសិក្សាថ្នាក់បឋម និងមធ្យម ដើម្បីជំរុញ និងបន្តការអប់រំរបស់ពួកគេ និងដើម្បីកែលម្អមូលដ្ឋានគ្រឹះនៃការអប់រំនៅតំបន់ជនបទ និងតំបន់ដែលមានភាពខ្វះខាតខ្សោយនៃប្រទេសកម្ពុជា ដោយកំណត់គោលដៅអភិវឌ្ឍន៍សាលារៀន ការបញ្ជូនគ្រូបង្រៀនតាមការសមស្រប បរិក្ខារ អគារ និងហេដ្ឋារចនាសម្ព័ន្ធអប់រំទាំងមូល។

អង្គការមានទីតាំងស្ថិតនៅអគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

## ២. គោលនយោបាយគណនេយ្យ

### ២.១ មូលដ្ឋាននៃការរៀបចំ

អង្គការនេះត្រូវបានចុះបញ្ជីជាមួយ និងទទួលបានអាជ្ញាបណ្ណពីក្រសួងមហាផ្ទៃ ស្របតាមតម្រូវការនៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា។ ដូច្នេះហើយ អង្គការប្រកាន់ខ្ជាប់នូវក្របខណ្ឌរបាយការណ៍ហិរញ្ញវត្ថុ ដែលអនុវត្តចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ ("CFRS for NFPEs") ដែលចេញផ្សាយដោយនិយ័តករគណនេយ្យ និងសវនកម្ម ស្របតាមប្រកាសលេខ ៣៣៥ ស្តីពីការអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជា សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨ ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

គោលនយោបាយគណនេយ្យចម្បងដែលត្រូវបានអនុម័តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុត្រូវបានកំណត់ដូចខាងក្រោម។ គោលនយោបាយគណនេយ្យទាំងនេះត្រូវបានអនុវត្តជាប់លាប់ចំពោះការិយបរិច្ឆេទទាំងអស់ដែលបានបង្ហាញ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

រាល់ប្រតិបត្តិការទាំងអស់ត្រូវបានរាយការណ៍នៅក្នុងរបាយការណ៍ចំណូល និងចំណាយ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ។

## ២.២ រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់បង្ហាញ

រូបិយវត្ថុជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺខ្មែររៀល ("KHR")។ ប៉ុន្តែដោយសារក្រុមហ៊ុនមានប្រតិបត្តិការអាជីវកម្ម និងការរក្សាកំណត់ត្រាគណនេយ្យបឋមជាដុល្លារអាមេរិក ("USD") គណៈគ្រប់គ្រងបានកំណត់យករូបិយប័ណ្ណដុល្លារអាមេរិកជារូបិយប័ណ្ណរបស់អង្គការសម្រាប់គោលបំណងនៃការវាស់វែង និងបង្ហាញព្រោះវាបានឆ្លុះបញ្ចាំងពីខ្លឹមសារសេដ្ឋកិច្ចនៃព្រឹត្តិការណ៍ និងស្ថានការណ៍របស់អង្គការ។

ប្រតិបត្តិការជារូបិយប័ណ្ណបរទេសក្រៅពីដុល្លារអាមេរិក ត្រូវបានប្តូរទៅជាដុល្លារអាមេរិក ដោយប្រើប្រាស់អត្រាប្តូរប្រាក់ទូទៅនាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ទ្រព្យសកម្ម ឬបំណុលរូបិយវត្ថុដែលកំណត់ជារូបិយប័ណ្ណក្រៅពីដុល្លារអាមេរិកនាកាលបរិច្ឆេទនៃរបាយការណ៍ត្រូវបានប្តូរទៅជាដុល្លារអាមេរិកដោយប្រើប្រាស់អត្រាប្តូរប្រាក់ទូទៅ នាកាលបរិច្ឆេទនៃរបាយការណ៍។ លម្អៀងពីការប្តូររូបិយប័ណ្ណ ដែលបានកើតឡើងពីការប្តូរប្រាក់ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូល និងចំណាយ។

ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិក ទៅជាខ្មែររៀលដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានដាក់បញ្ចូលទាំងស្រុងដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ហើយត្រូវបានធ្វើឡើងដោយប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការដោយផ្អែកលើអត្រាប្តូរប្រាក់ដែលអាចប្រើប្រាស់បានក្នុង ១ដុល្លារអាមេរិក ដែលបានប្រកាសដោយធនាគារជាតិ នៃ កម្ពុជា ដូចខាងក្រោម៖

| | **ឆ្នាំ២០២៣** | ឆ្នាំ២០២២ |
|---|---|---|
| អត្រាប្តូរប្រាក់ជាមធ្យម* | **៤.១១០** | ៤.០៨៧ |
| អត្រាប្តូរប្រាក់ចុងគ្រា | **៤.០៨៥** | ៤.១១៧ |

*អត្រាប្តូរប្រាក់ជាមធ្យម គឺត្រូវបានកំណត់ដោយផ្អែកតាមអត្រាប្តូរប្រាក់ប្រចាំថ្ងៃចុងគ្រាក្នុងអំឡុងការិយបរិច្ឆេទ។

អត្រាប្តូរប្រាក់ទាំងនេះ មិនត្រូវបានធ្វើសវនកម្ម និងមិនត្រូវបានបកស្រាយថា ជាតំណាងនៃប្រាក់ដុល្លារអាមេរិក ឬដែលត្រូវបាន ឬអាចនឹងត្រូវបាន ឬអាចប្តូរទៅជាប្រាក់រៀលនៅថ្ងៃអនាគតតាមអត្រាដែលបានបង្ហាញនេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតឡើយ។

## ២.៣ ចំណូល

ចំណូលរួមមានសាច់ប្រាក់ទាំងអស់ដែលទទួលបានក្នុងអំឡុងការិយបរិច្ឆេទ ហើយត្រូវបានទទួលស្គាល់ជាចំណូលសរុបនៃសេវារបស់ធនាគារ។ សាច់ប្រាក់ដែលទទួលបានទាក់ទងនឹងសកម្មភាពទូទៅរបស់អង្គការត្រូវបានទទួលស្គាល់ថាជាចំណូលកិច្ចប្រតិបត្តិការស្របពេលដែលសាច់ប្រាក់ដែលទទួលបានពីការលក់ធនធាន និងប្រាក់កម្ចីត្រូវបានទទួលស្គាល់ជាចំណូលមូលធន។

### ចំណូលបានពីការបរិច្ចាគ

ការបរិច្ចាគកើតឡើងពីចំណូលមូលនិធិពីម្ចាស់ជំនួយផ្សេងៗ រួមទាំងបុគ្គលិករបស់ធនាគារអេស៊ីលីដា ភីអិលស៊ី និងបុគ្គលខាងក្រៅដែលស្គាល់គម្រោង និងកម្មវិធីរបស់អង្គការ។

### ២.៤ ចំណាយ

ចំណាយរួមមានប្រាក់ទាំងអស់ដែលបានទូទាត់ក្នុងអំឡុងការិយបរិច្ឆេទ។ ចំណាយដែលធ្វើឡើងទាក់ទងនឹងការចំណាយទាំងអស់ដើម្បីគាំទ្រដល់គោលបំណងរបស់អង្គការត្រូវបានកត់ត្រាជាការចំណាយប្រតិបត្តិការ ខណៈពេលដែលការទូទាត់ដែលបានធ្វើឡើងដើម្បីទិញធនធាន ទ្រព្យសកម្មរូបី ការវិនិយោគ និងប្រាក់កម្ចីដែលត្រូវបានទទួលស្គាល់ថាជាការចំណាយមូលធន។

**អំណោយ - អគារ និងបរិក្ខារសិក្សា**

នេះតំណាងឱ្យការចំណាយលើការបរិច្ចាគ ស្របតាមគោលបំណងរបស់អង្គការ។ អំណោយរួមមានការសាងសង់សាលាបឋមសិក្សានៅតាមខេត្តមួយចំនួនក្នុងប្រទេសកម្ពុជា និងសម្ភារសិក្សាសម្រាប់សាលារៀននៅតំបន់ដាច់ស្រយាល។

### ២.៥ ភាគីពាក់ព័ន្ធ

ប្រតិបត្តិការភាគីពាក់ព័ន្ធ គឺជាការផ្ទេរមូលនិធិ ឬធនធានផ្សេងទៀតរវាងអង្គការ និងភាគីពាក់ព័ន្ធរបស់ខ្លួន។ ភាគីពាក់ព័ន្ធ គឺជាបុគ្គល និងអង្គភាពដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយអង្គការ និងមានឥទ្ធិពលយ៉ាងសំខាន់លើអង្គការ។

### ២.៦ ពន្ធលើប្រាក់ចំណូល

នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ អង្គការបានទទួលលិខិតអនុម័តពីអគ្គនាយកដ្ឋានពន្ធដារសម្រាប់ការអនុគ្រោះពន្ធលើប្រាក់ចំណូលចំពោះជំនួយ និងមូលនិធិដែលអង្គការបានទទួល។ អង្គការត្រូវបានរៀបចំ និងដំណើរការសម្រាប់គោលបំណងមនុស្សធម៌សុទ្ធសាធ និងមិនស្វែងរកប្រាក់ចំណេញ ហើយពុំមានចំណែកនៃទ្រព្យសម្បត្តិ ឬប្រាក់ចំណូល សម្រាប់ប្រើប្រាស់ក្នុងគោលបំណងឯកជនឡើយ។ ការលើកលែងពន្ធនេះគឺជាការអនុលោមតាមមាត្រា ៦ ថ្មីនៃប្រកាសស្តីពីការអនុវត្តកាតព្វកិច្ចពន្ធដាររបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

***អាករលើតម្លៃបន្ថែម ("អតប")***

អង្គការមិនត្រូវបានចុះបញ្ជីសម្រាប់អាករលើតម្លៃបន្ថែមទេ។ ដូច្នេះហើយ សមតុល្យដែលបានកត់ត្រាក្នុងរបាយការណ៍ហិរញ្ញវត្ថុ គឺរួមបញ្ចូលអាករលើតម្លៃបន្ថែម ប្រសិនបើមាន។

## ៣. ចំណូលការប្រាក់ និងចំណូលផ្សេងៗ

| | **សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ២.២)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.២) |
| ចំណូលការប្រាក់ពីគណនីបញ្ញើមានកាលកំណត់ | **៣៦.៣៨៥** | **១៤៩.៥៤៣** | ៣០.៤១១ | ១២៤.២៩០ |
| ចំណូលការប្រាក់ពីគណនីសន្សំ | **៦៥៧** | **២.៧០០** | ៤៩៤ | ២.០១៩ |
| ចំណេញបានពីការប្តូររូបិយប័ណ្ណបរទេស - សុទ្ធ | **៤** | **១៦** | ៥ | ២០ |
| | **៣៧.០៤៦** | **១៥២.២៥៩** | ៣០.៩១០ | ១២៦.៣២៩ |

## ៤. ការចំណាយរដ្ឋបាល

| | **សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ២.២)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.២) |
| ការគ្រប់គ្រងកម្មវិធី* | **៩.៥០៣** | **៣៩.០៥៧** | - | - |
| ថ្លៃជួល | **១.២៧២** | **៥.២២៨** | - | - |
| សេវាផ្នែកច្បាប់ និងវិជ្ជាជីវៈ | **១.០៩៨** | **៤.៥១៣** | ៤.០៨៤ | ១៦.៦៩១ |
| ពន្ធប៉ាតង់ | **២៩២** | **១.២០០** | ២៩៤ | ១.២០២ |
| ផ្សេងៗ | **២៦៤** | **១.០៨៥** | ២៥៣ | ១.០៣៤ |
| | **១២.៤២៩** | **៥១.០៨៣** | ៤.៦៣១ | ១៨.៩២៧ |

*ការគ្រប់គ្រងកម្មវិធីរួមមានការចំណាយទាក់ទងនឹងពិធីបើកសម្ពោធសាលាថ្មីចំនួន ១១ ខ្នងក្នុងឆ្នាំ២០២៣។

## ៥. ចំណាយទាក់ទងនឹងអ្នកស្ម័គ្រចិត្ត និងនិយោជិត

| | **សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ២.២)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.២) |
| ចំណាយលើធានារ៉ាប់រង | - | - | ១.៥០១ | ៦.១៣៥ |

## ៦. សាច់ប្រាក់ក្នុងធនាគារ

| | **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ២.២)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.២) |
| គណនីប្រាក់បញ្ញើមានកាលកំណត់ | **៧៩០.០០០** | **៣.២២៧.១៥០** | ៨៥០.០០០ | ៣.៤៩៩.៤៥០ |
| គណនីសន្សំ | **៤១.១៦២** | **១៦៨.១៤៧** | ៩៥.៨៨៧ | ៣៩៤.៧៦៧ |
| | **៨៣១.១៦២** | **៣.៣៩៥.២៩៧** | ៩៤៥.៨៨៧ | ៣.៨៩៤.២១៧ |

សាច់ប្រាក់ក្នុងធនាគារទទួលបានការប្រាក់នៅពេលដាក់ប្រាក់បញ្ញើមានកាលកំណត់តាមធនាគារដែលមានអត្រាជាមធ្យមចាប់ពី ៤,៥០% - ៥,៥០% ក្នុងមួយឆ្នាំ (ឆ្នាំ២០២២៖ ១,០០% - ៤,៧៥% ក្នុងមួយឆ្នាំ) និងពីគណនីសន្សំក្នុងអត្រា ០,២៥% ក្នុងមួយឆ្នាំ (ឆ្នាំ២០២២៖ ០,២៥ ក្នុងមួយឆ្នាំ)។

## ៧ ប្រាក់តម្កល់តាមបទប្បញ្ញត្តិ

យោងតាមប្រកាសលេខ ០០៣ ចេញថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ បរធនបាលកិច្ចបុគ្គលរបស់អង្គការ ដែលតំណាងឱ្យអង្គការ ត្រូវប្រគល់ថ្លៃអាជ្ញាបណ្ណទៅឱ្យនិយ័តករបរធនបាលកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជាចំនួន ១៦លានរៀល ដូចមានចែងក្នុងដីកាលេខ ៥៣៨/២២ ចេញថ្ងៃទី៨ ខែតុលា ឆ្នាំ២០២២ រួមជាមួយនឹងប្រាក់តម្កល់ចំនួន ៨០លានរៀល សម្រាប់ការធានាដើមទុនតាមដីកាលេខ ៤៣៩/២២។

គោលបំណងនៃការទទួលបានអាជ្ញាបណ្ណអាណត្តិគាហកនេះគឺដើម្បីអោយគណៈគ្រប់គ្រងទទួលបានមូលនិធិយ៉ាងច្រើនពីក្រៅប្រទេស ដើម្បីជួយដល់សិស្សានុសិស្សដែលរស់នៅក្នុងតំបន់ជនបទក្នុងការទទួលបានការអប់រំតាមរយៈការផ្តល់អគារ និងសម្ភារសិក្សា។

## ៨ របាយការណ៍នៃប្រភពធនធាន និងកិច្ចសន្យា

| | កំណត់សម្គាល់ | **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ដុល្លារអាមេរិក** | **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ពាន់រៀល (កំណត់សម្គាល់ ២.២)** | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដុល្លារអាមេរិក | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ពាន់រៀល (កំណត់សម្គាល់ ២.២) |
|---|---|---|---|---|---|
| **ធនធានមានកាលវិភាគកំណត់** | | | | | |
| សាច់ប្រាក់ក្នុងធនាគារ | ៦ | **៨៥០.៤៨៦** | **៣.៤៧៤.២៣៦** | ៩៦៥.២១១ | ៣.៩៧៣.៧៧៤ |
| ប្រាក់តម្កល់តាមបទប្បញ្ញត្តិ | | **១៩.៣២៤** | **៧៨.៩៣៩** | ១៩.៣២៤ | ៧៩.៥៥៧ |
| ការប្រាក់ត្រូវទទួលពីសាច់ប្រាក់ក្នុងធនាគារ | | **១២** | **៤៩** | ៦៣ | ២៥៩ |
| **កិច្ចសន្យាមានកាលវិភាគកំណត់** | | | | | |
| ពន្ធកាត់ទុកត្រូវបង់ | | **២២១** | **៩០៣** | ៤៤០ | ១.៨១១ |
| ថ្លៃឈ្នួលត្រូវបង់ | | - | - | ១១៤ | ៤៦៩ |
| កិច្ចសន្យាផ្សេងៗ | ១០ | **៤៩.៣៧២** | **២០១.៦៨៥** | ១៩.១៧៧ | ៧៨.៩៥២ |

## ៩. សមតុល្យ និងប្រតិបត្តិការរបស់ភាគីពាក់ព័ន្ធ

ភាគីពាក់ព័ន្ធ និងទំនាក់ទំនងរបស់ពួកគេជាមួយអង្គការមានដូចខាងក្រោម៖

| **ភាគីពាក់ព័ន្ធ** | **ទំនាក់ទំនង** |
|---|---|
| ធនាគារ អេស៊ីលីដា ភីអិលស៊ី | ស្ថាបនិក |
| ក្រុមហ៊ុនហ្វតតេ អ៊ិនសួរ៉ីនស៍ (ខេមបូឌា) ភីអិលស៊ី | ស្ថាបនិក |
| បណ្ឌិត ព្រុំ វិសុទ្ធ | ប្រធានក្រុមប្រឹក្សាភិបាល |

សមតុល្យខាងក្រោមគឺជាសមតុល្យដែលនៅជំពាក់ភាគីពាក់ព័ន្ធ៖

| **ភាគីពាក់ព័ន្ធ** | **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ដុល្លារអាមេរិក** | **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ពាន់រៀល (កំណត់សម្គាល់ ២.២)** | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដុល្លារអាមេរិក | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ពាន់រៀល (កំណត់សម្គាល់ ២.២) |
|---|---|---|---|---|
| **សាច់ប្រាក់ក្នុងធនាគារ** | | | | |
| ធនាគារ អេស៊ីលីដា ភីអិលស៊ី | ៨៥០.៤៨៦ | ៣.៤៧៤.២៣៦ | ៩៦៥.២១១ | ៣.៩៧៣.៧៧៤ |

ក្នុងអំឡុងការិយបរិច្ឆេទ ប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធត្រូវបានកត់ត្រាដូចខាងក្រោម៖

| **ភាគីពាក់ព័ន្ធ** | **ប្រតិបត្តិការ** | **សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
|---|---|---|---|---|---|
| | | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ២.២)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.២) |
| ក្រុមហ៊ុនហ្វតេ អ៊ិនស្វីរែនស៍ (ខេមបូឌា) ភីអិលស៊ី | ចំណូលពីការបរិច្ចាគ | **៣០.០០០** | **១២៣.៣០០** | - | - |
| ធនាគារ អេស៊ីលីដា ភីអិលស៊ី | ចំណូលការប្រាក់ | **៣៧.០៤២** | **១៥២.២៤៣** | ៣០.៩០៥ | ១២៦.៣០៩ |
| | ចំណូលពីការបរិច្ចាគ | - | - | ១៥០.០០០ | ៦១៣.០៥០ |
| បណ្ឌិត ព្រំ វិសុទ្ធ | ការបរិច្ចាគដែលប្រមូលបានជំនួសឱ្យ អេ ជេ អេហ្វ | - | - | ៨៥ | ៣៤៧ |
| | ការទូទាត់នៃការបរិច្ចាគដែលប្រមូលបានជំនួសឱ្យ អេ ជេ អេហ្វ | - | - | ២.៩៩៦ | ១២.២៤៥ |

## ១០. កិច្ចសន្យាផ្សេងៗ

ក្នុងអំឡុងការិយបរិច្ឆេទ អង្គការបានចុះកិច្ចសន្យាក្នុងការសាងសង់ និងជួសជុលអគារសាលារៀន និងសម្ភារសិក្សានានា ជាមួយនឹងតម្លៃកិច្ចសន្យាសរុបមានដូចខាងក្រោម៖

| | **សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ២.២)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.២) |
| អគារ និងសម្ភារសិក្សា | **៤៤.៥៥១** | **១៨១.៩៩១** | ១៩.១៧៧ | ៧៨.៩៥២ |

## ១១. ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទនៃរបាយការណ៍

ពុំមានព្រឹត្តិការណ៍សំខាន់ៗដែលបានកើតឡើងបន្ទាប់ពីចុងការិយបរិច្ឆេទនៃរបាយការណ៍ និងកាលបរិច្ឆេទនៃការអនុម័តទៅលើរបាយការណ៍ហិរញ្ញវត្ថុទាំងនេះដែលតម្រូវឱ្យមានការកែតម្រូវ ឬការលាតត្រដាងព័ត៌មានដែលត្រូវបានធ្វើឡើងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុឡើយ។

## ១២. ការអនុម័តទៅលើរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុរបស់អង្គការគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ត្រូវបានអនុម័តឱ្យចេញផ្សាយដោយគណៈគ្រប់គ្រងនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤។